# បន្លាក្នុងទ្រូង:
# បុរសខ្មែរដែលទិញសេវាផ្លូវភេទ

ដោយ: Melissa Farley, Wendy Freed, គៀនសិរីផល ,

Jaqueline Golding



បង្ហាញនៅក្នុងសន្និសីទ ដែលរៀបចំរួមគ្នាដោយ

អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ និង អង្គការអប់រំ និងស្រាវជ្រាវអំពីពេស្យាចារ

ផ្តោតទៅលើ បុរសដែលទិញសេវាផ្លូវភេទ:

បង្អាក់ទឹកចិត្តបុរសពីតម្រូវការសេវាផ្លូវភេទ  បញ្ឈប់ការជួញដូរផ្លូវភេទ

ថ្ងៃទី ១៧ខែកក្កដា ឆ្នាំ២០១២ ភ្នំពេញ កម្ពុជា

# បន្ទាក្នុងទ្រូង: បុរសខ្មែរដែលទិញសេវាផ្លូវភេទ

*ដោយ:***Melissa Farley, Wendy Freed, គៀន សិរីផល, Jacqueline Golding**

*បង្ហាញនៅក្នុងសន្និសីទស្តីអំពី:*

*ផ្តោតទៅលើ បុរសខ្មែរដែលទិញសេវាផ្លូវភេទ: បង្អាក់ទឹកចិត្តបុរសពីតម្រូវការសេវាផ្លូវភេទ បញ្ឈប់ការជួញដូរផ្លូវភេទ*

*សន្និសីទដែលរៀបចំរួមគ្នាដោយ អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ និង អង្គការអប់រំ និងស្រាវជ្រាវអំពីពេស្យាចារ*

*ថ្ងៃទី ១៧ខែកក្កដា ឆ្នាំ២០១២ ភ្នំពេញ កម្ពុជា*

*ឯកសារនេះអាចរកបាននៅ* www.prostitutionresearch.com *និងនៅ* www.cwcc.org.kh

# មាតិកា

មាតិកា.............................................................................................

តារាងទី១. សម្រង់ពាក្យពេចន៍ ពីអ្នកទិញសេវាផ្លូវភេទ ......................................

អត្ថបទសង្ខេប .. ..............................................................................................
សេចក្តីថ្លែងអំណរគុណ.......................................................................................
សេចក្តីផ្តើម . ................. ..........................................................................................
ឥរិយាបថជាប្រពៃណី ចំពោះស្ត្រី និងបញ្ហាផ្លូវភេទ នៅកម្ពុជា ..................
ការរំលោភ ................................................................................
អំពើហឹង្សាក្នុងគ្រួសារ...............................................................
អំពើហឹង្សានៅក្នុងពេស្យាចារ........................................................
ការរំលោភបូក ...............................................................................
រូបភាពវីដេអូផ្លូវភេទ .....................................................................
រូបភាពវីដេអូផ្លូវភេទអំពីកុមារ នៅកម្ពុជា .............................................
ប្រវត្តិថ្មីៗនៃពេស្យាចារ និងឧស្សាហកម្មផ្លូវភេទនៅកម្ពុជា .........................
ការឆ្លើយតបផ្លូវច្បាប់ ចំពោះការរំលោភផ្លូវភេទ ដោយរួមទាំងការជួញដូរមនុស្ស
ទៅក្នុងអំពើពេស្យាចារ ....................................................................

វិធីសាស្ត្រ ..........................................................................................
ការបណ្តុះបណ្តាលអ្នកសម្ភាសន៍ និងគាំទ្រ ..................................................

លទ្ធផល.................................................................................................................
លក្ខណៈប្រជាសាសន៍របស់បុរសខ្មែរ១៣៣នាក់ ដែលបានទិញសេវាផ្លូវភេទ.......
តារាងទី២. អាយុបុរសខ្មែរ១៣៣នាក់ដែលបានទិញសេវាផ្លូវភេទ.......................................

*តារាងទី៣. ប្រាក់ចំណូលគ្រួសារ បុរសខ្មែរ១៣៣នាក់ដែលបានទិញសេវាផ្លូវភេទ........*

*តារាងទី៤. កំរិតនៃការសិក្សារបស់បុរសខ្មែរ១៣៣នាក់ដែលបានទិញសេវាផ្លូវភេទ........*

ជាតិពន្ធ ..................................................................................

ដៃគូរួមភេទ...............................................................................

*តារាងទី៥. ចំនួនដៃគូរួមភេទក្នុងពាក់ជីវិត របស់បុរសខ្មែរ១៣៣នាក់ដែលបានទិញសេវាផ្លូវភេទ.........................................................................................*

**បទពិសោធន៍ក្រោមរបបខ្មែរក្រហម ...................................................**

**ឥរិយាបថពេស្យាចាររបស់អ្នកទិញសេវាផ្លូវភេទខ្មែរ.........................................**

ការប្រើប្រាស់ស្ត្រីរកស៊ីផ្លូវភេទលើកដំបូង........................................................

ការជ្រើសរើសជាតិពន្ធ និងអាយុ របស់ស្ត្រីរកស៊ីផ្លូវភេទ .........................................

ភាពញឹកញាប់នៃការទិញសេវាផ្លូវភេទ ..............................................................

តើបុរសនៅកម្ពុជាស្វែងរកនារីនៅទីណា ដើម្បីទិញសេវាផ្លូវភេទ ? .....................

*តារាងទី៦. តំបន់ផ្ទះបន ដែលបុរសខ្មែរទិញសេវាផ្លូវភេទ.......................................................*

ការធ្វើដំណើរទៅទិញេសវាផ្លូវភេទនៅក្នុង និងក្រៅប្រទេសកម្ពុជា .....................

ការប្រើប្រាស់ថ្នាំញៀន និងគ្រឿងស្រវឹងរបស់អ្នកទិញសេវាផ្លូវភេទខ្មែរ .............

ប្រវត្តិយោធា របស់អ្នកទិញសេវាផ្លូវភេទ ........................................................

ការចំនាយលើសេវាផ្លូវភេទដោយប្តូរជាថ្នាំញៀន ជម្រក ម្ហូបអាហារ និង សំលៀកបំពាក់ ..............................................................................

បុរសខ្មែរនិយាយពីមូលហេតុដែលទិញសេវាផ្លូវភេទ............................................

ស្វ័យរាយការណ៍ពី អំពើហឹង្សាផ្លូវភេទ .......................................................

**ឥរិយាបថ និងជំនឿ របស់អ្នកទិញសេវាផ្លូវភេទ..............................................**

ទង្វើរមិនសមនិស្ស័យជាមនុស្ស ទៅលើស្ត្រីក្នុងរបរផ្លូវភេទ ...............................

ជំនឿដែលថារបរផ្លូវភេទ ការពារ/កាត់បន្ថយអំពើរំលោភសេពសន្ថវៈ ...............

បុរសដែលបង្ហាញចេញនូវអត្តសញ្ញាណជាអ្នកត្រួតត្រា ការទទួលយកពីរឿង
មិនពិតនៃពេស្យាចារ ការទទួលយកពីរឿងមិនពិតនៃការរំលោភ ............
យល់ដឹងអំពី មេបន ការបង្ខិតបង្ខំ និងការជួញដូរ ........................................................
រឿងមិនពិតអំពីផ្លូវភេទ ដែលមានក្នុងចំណោមអ្នកទិញសេវាផ្លូវភេទ …………....
គ្មានការយល់ចិត្ត ចំពោះស្ត្រីក្នុងរបរផ្លូវភេទ ..................................................................
*តារាងទី៧. ពាក្យពេចន៍ដែលប្រើ ដោយអ្នកទិញសេវាផ្លូវភេទ និងស្ត្រីរកស៊ីផ្លូវភេទ*
*ដើម្បីពណ៌នាពីអារម្មណ៍របស់ស្ត្រីក្នុងពេលក្នុងពេលបំរើសេវា*. …....…...… …. ….....
គ្មានទំនាក់ទំនងខាងអារម្មណ៍ ជាមួយស្ត្រីរកស៊ីផ្លូវភេទ...............................................
វិវាទផ្ទៃក្នុងនៃអ្នកទិញសេវាផ្លូវភេទ ..........................................................................

ការប្រើប្រាស់វីដេអូផ្លូវភេទ …………...............................................................................
*រូបភាពវីដេអូរួមភេទដោយតាមមាត់*...................................................................................
*រូបភាពវីដេអូរួមភេទតាមយោនី*.......................................................................................
*រូបភាពវីដេអូភេទតាមរន្ធគូថ*.........................................................................................
*រូបភាពវីដេអូរួមភេទតាមមាត់និងឈូក់* .............................................................................
*រូបភាពវីដេអូរួមភេទជាក្រុម*........................ ......................................................................
*រូបភាពវីដេអូរួមភេទជាក្រុម ដោយមានបុរសលើសពីម្នាក់ ដាក់បញ្ចូលលឹង្គទៅក្នុងយោនី*
*រន្ធគូថ និង/ឬមាត់របស់ស្ត្រី ឬក្មេងស្រី*..................... ..................... .......................
*រូបភាពវីដេអូរួមភេទរបស់ស្ត្រី ឬក្មេងស្រី ដែលញញឹម*............................... ........................
*រូបភាពវីដេអូរួមភេទរបស់ស្ត្រី ឬក្មេងស្រី ដែលមិនញញឹម*.......................... .......................
*រូបភាពវីដេអូរួមភេទរបស់ស្ត្រី ឬក្មេងស្រី ដែលយំ* ....................................... .......................
*រូបភាពវីដេអូរួមភេទរបស់មនុស្សពេញវ័យ ដែលរួមភេទជាមួយកុមារ*..... .......................
*រូបភាពវីដេអូរួមភេទ របស់ស្ត្រី ឬក្មេងស្រី ដែលរួមភេទជាមួយសត្វ*......... .......................
*រូបភាពវីដេអូរួមភេទ រំលោភបូក* ......... ...................................................................................
*រូបភាពវីដេអូរួមភេទ* **Bukkake** *(បុរសបញ្ចេញទឹកកាមលើមុខរបស់ស្ត្រី)* .................
*រូបភាពវីដេអូរួមភេទតាមរន្ធគូថ និងមាត់*................ ....................................................................
*រូបភាពវីដេអូរួមភេទរបស់ស្ត្រី ឬក្មេងស្រី ដែលត្រូវគេចង*..........................................................

រូបភាពវីដេអូរួមភេទ ដែលធ្វើឲ្យខក់ (ឈ្ងក់) ........................................................................................
រូបភាពវីដេអូរួមភេទ ដែលសម្លាប់ដោយចង់ករ........................................................................................
រូបភាពវីដេអូរួមភេទ ដោយការធ្វើទារុណ្ណកម្ម........................................................................................
រូបភាពវីដេអូរួមភេទ ដោយមានការធ្វើឃាត........................................................................................
អំពើរំលោភបូកក្នុងពេស្យាកម្ម និងរូបភាពវីដេអូរួមភេទបូក ..........................................................

ការបង្អាក់ទឹកចិត្តចំពោះការទៅរកសេវាផ្លូវភេទ ..........................................................
តារាងទី៨. ការឆ្លើយតបរបស់បុរសទាំង១៣៣នាក់ ចំពោះសំណួរ ថា "តើមានអ្វីដែល អាចរារាំងអ្នក ពីការទិញសេវាផ្លូវភេទ" ..........................................................

សេចក្ដីសង្ខេប និងអនុសាសន៍ ........................................................................................
ឯកសារយោង .......................................................... ..........................................................

ឧបសម្ព័ន្ធ ក. ការរៀបតាមលំដាប់លំដោយនៃជាតិពន្ធ របស់ស្ត្រី និង កុមារនៅក្នុង វីដេអូរួមភេទ ដែលបានរៀបរាប់ជាញឹកញាប់ដោយអ្នកទិញសេវាផ្លូវភេទទាំង ១៣៣ នាក់នៅកម្ពុជា

តារាងទី១. សម្រង់ពាក្យពេចន៍ ពីអ្នកទិញសេវាផ្លូវភេទជាខ្មែរ

| |
|---|
| "ផ្ទះបន គឺជាឋានសួគ៌របស់បុរស ប៉ុន្តែវាជាឋាននរករបស់ស្ត្រីទាំងនោះ" |
| "មិត្តរបស់ខ្ញុំបាននាំស្ត្រីម្នាក់ទៅរំលោភ រួចក៏ចែកនាងទៅឲ្យមិត្តភក្តិគាត់ផ្សេងៗទៀតរំលោភ ដែរ" |
| " (ការទិញសេវាផ្លូវភេទ) វាគ្មានរឿងរ៉ាវអ្វីទេ ពីព្រោះយើងមិនមែនរំលោភកូនក្រមុំគេឯណា" |
| "ស្រីដែលយកមករួមភេទបូក គឺស្រីដែលគេហៅថាអស់សាច់ លែងខ្វល់ខ្វាយ ហើយអស់សង្ឃឹមក្នុងជីវិត ចេះតែបណ្តោយខ្លួនទៅ" |
| " បើយើងសង្កេតឲ្យដិតដល់ យើងឃើញ មេបនមើលងាយមើលថោក ដេរប្រមាថស្ត្រី រកស៊ីផ្លូវភេទ ដាងសត្វធាតុ ដូចជា ឆ្កែ និងឆ្មា ទៅទៀត" |
| " នៅពេលយើងទៅដល់ផ្ទះបន យើងនិយាយតថ្លៃជាមួយមេបន ហាក់ដូចជាយើងតថ្លៃទិញកូនជ្រូកអញ្ចឹង " |
| "មើលការរំលោភបូកនៅក្នុងវីដេអូ ស្ត្រីតែងតែយល់ព្រមឱ្យគេរំលោភបូក ប៉ុន្តែនៅកម្ពុជាស្ត្រីដែលត្រូវគេរំលោភបូក គឺតែងតែទទួលរងការវាយដំ " |
| " ខ្ញុំគិតថានាងយល់ព្រម (ឱ្យគេរួមភេទបូក) ពីព្រោះនាងខ្លាចគេ ឬត្រូវការថវិកា" |
| " អំណាចទាំងអស់ គឺនៅស្ថិតក្នុងដៃមេបន ឯស្ត្រីរកស៊ីផ្លូវភេទវិញ គឺគ្រាន់តែជាម៉ាស៊ីនដែលធ្វើតាមការបញ្ជាតែប៉ុណ្ណោះ " |

" បុរសខ្លះនៅពេលគេ ប្រច័ណ្ឌនឹងសង្សារ ឬប្រពន្ធរបស់គេ  គឺច្រើនតែដេរដៀល ឬប្រៀបធៀប សង្សារ ឬប្រពន្ធរបស់គេ ទៅនឹងស្ត្រីរកស៊ីផ្លូវភេទ ។  នោះគឺដោយសារតែស្ត្រីរកស៊ីផ្លូវភេទ គ្មានឋានៈ នៅក្នុងសង្គម "

" ខ្ញុំជូនម្តាយមីងរបស់ខ្ញុំ ទៅវៀតណាម ដើម្បីព្យាបាលជំងឺតម្រងនោមរបស់គាត់ ហើយនៅពេលដែលទំនេរ ខ្ញុំទៅផ្ទះបន"

" ពួកយើងជាបុរស  គឺជាអ្នកទិញ  ឯស្ត្រីរកស៊ីផ្លូវភេទគឺជាទំនិញ  ហើយមេបន គឺដូចជាអ្នកលក់អញ្ចឹង "

" បើសិនជាមានស្ត្រីរកស៊ីផ្លូវភេទ  យើងមិនអាចបញ្ឈប់ខ្លួនឯងមិនឱ្យទៅផ្ទះបនបានទេ..... ពីព្រោះ ស្ត្រីជាទំពក់ដែលថ្ពក់ទាញបុរសឲ្យចង់រួមភេទ "

" ដ៏រាបណា គំលាតរវាងអ្នកមាន និងអ្នកក្រនៅតែមាន  ដ៏រាបណាស្ត្រី និង បុរស នៅតែមានស្ថានភាពសង្គម មិនស្មើគ្នា  ខ្ញុំយល់ថាមុខរបរបែបនេះ នឹងនៅតែកើតមាននៅក្នុងសង្គម "

## អត្ថបទសង្ខេប

*យើងបានសម្ភាសន៍បុរសខ្មែរចំនួន ១៣៣នាក់ ដែលបានទិញសេវាផ្លូវភេទពីស្ត្រីរកស៊ីផ្លូវភេទដែលពេញវ័យ ហើយក៏មាន៣៧%ដែលបានទទួលស្គាល់ថាខ្លួនបានទិញសេវាផ្លូវភេទពីក្មេងស្រីដែលមិនទាន់គ្រប់អាយុ ។ បុរសដែលបានសម្ភាសន៍នៅក្នុងការសិក្សានេះស្ទើរតែទាំងអស់ (៩៥%) បាននិយាយថាមានកុមារដែលគេបង្ខំឲ្យរួមភេទយកលុយ នៅក្នុងផ្ទះបន រង្គសាល កន្លែងម៉ាសារក្នុងរាជធានីភ្នំពេញ ។ ដើម្បីរាស់ស្ទង់ពីឥរិយាបថ និងការប្រព្រឹត្ត របស់បុរស យើងបានប្រើ បញ្ជីរសំណួរដែលធ្លាប់បានប្រើពីមុន ដែលបានផ្ទៀងផ្ទាត់ពីភាពត្រឹមត្រូវ មាន លក្ខណៈស្តង់ដារ ហើយរៀបចំការសំភ្ភាសន៍តាម លំដាប់លំដោយនៃបញ្ជីសំណួរ ដែលនាំមកនូវទិន្នន័យទាំងពីរផ្នែក គឺទាំងទិន្នន័យផ្នែកបរិមាណ និងគុណភាព ។ ការសម្ភាសន៍និមួយៗ ចំណាយពេលប្រហែលជា ២ ទៅ ៣ ម៉ោង ធ្វើឡើងដោយក្រុមអ្នកសម្ភាសន៍ចំនួន ៨ នាក់ ដែលបានទទួលការបណ្តុះបណ្តាលជាពិសេស។ បុរសភាគច្រើនបាននិយាយថា គេមានប្រពន្ធ ឬសង្សាររួចទៅហើយ នៅពេលដែលគេទៅរកស្ត្រីរកស៊ីផ្លូវភេទ។ ពួកគេបានរាយការណ៍ឲ្យដឹងថា គេមានដៃគូរួមភេទជាច្រើន នៅក្នុងជីវិតរបស់គេ (២១%មានដៃគូរួមភេទពី២១ ទៅ៥០នាក់ ហើយ៣៥%មានដៃគូរួមភេទពី៥០ នាក់ឡើងទៅ) ។ ស្ត្រីរកស៊ីផ្លូវភេទ គឺជាបទពិសោធន៍រួមភេទជាលើកដំបូងរបស់គេ សម្រាប់អ្នកដែលបានសម្ភាសន៍ភាគច្រើន ហើយពួកគេបាននិយាយថាការដែលគេទៅរកស្ត្រីរកស៊ីផ្លូវភេទ គឺដោយសារការអូសទាញពីមិត្តភក្តិ និងដើម្បីបង្ហាញពីភាពជាបុរសរបស់គេ ។ ភាគច្រើននៃបុរសដែលបានសម្ភាសន៍បានទិញសេវាផ្លូវភេទម្តងក្នុងមួយខែ ឬមានខ្លះក៏ច្រើនជាងម្តងក្នុងមួយខែ ។ ដូចបុរសនៅបណ្តាប្រទេសផ្សេងទៀតដែរ គេទិញសេវាផ្លូវភេទទាំងនៅក្នុងផ្ទះបន ឬនៅតាមផ្លូវ ។ បុរសស្ទើរតែទាំងអស់បានរាយការណ៍ថា បានទិញសេវាផ្លូវភេទពីផ្ទះបន ជាទីកន្លែងដែលគេបានឃើញនូវអំពើហឹង្សាឃោរឃៅ ការបង្ខិតបង្ខំ*

និងការគំរាមកំហែង - ដែលជាភស្តុតាងអាចបញ្ជាក់បានថាមានការជួញដូរមនុស្ស ទៅក្នុងរបរផ្លូវភេទ ។ អ្នកដែលបានសម្ភាសន៍ចំនួន ៣៩ ភាគរយ បានរៀបរាប់ថា បានឃើញការជួញដូរ ស្រ្តី និងកុមារ ។ បុរសដែលបានសម្ភាសន៍ស្ទើរតែទាំងអស់ បានទិញសេវាផ្លូវភេទពីស្រ្តី ដែលគ្រប់គ្រងដោយមេបន។ ជាញឹកញាប់បំផុត មេបន គឺជាស្រ្តី ប៉ុន្តែជួនកាល មេបនក៏ជាបុរសដែរ ។

នៅក្នុងការសម្ភាសន៍ទាំងនេះ បុរសមិនឲ្យតម្លៃជាមនុស្សដល់ស្រ្តី នៅក្នុងមុខរបរផ្លូវភេទទេ ដោយគេគិតថាពួកស្រ្តីទាំងនោះធ្វើឲ្យថោកទាប ទៅដល់ស្រ្តីផ្សេងៗទៀត ។ ពួកគេមានចេតនាស្តីបន្ទោសស្រ្តីរកស៊ីផ្លូវភេទ ថាជាអ្នកធ្វើឱ្យមានការឆ្លងរាលដាលមេរោគអេដស៍ ។ អ្នកទិញសេវាផ្លូវភេទជឿថា ពេស្យាចារ បង្ការ ឬកាត់បន្ថយការរំលោភសេពសន្ថវៈ ទោះបីជាគ្មានភស្តុតាង ចេញពីការពិសោធន៍ច្បាស់លាស់ចំពោះបញ្ហានោះក៏ដោយ ។ តាមការពិត អ្វីដែលផ្ទុយពីនោះវិញ គឺទំនងជាពិតជាង: សកម្មភាពជាមួយពេស្យាចាររបស់បុរស គឺទាក់ទងនឹងការកើនឡើងនៃការរំលោភសេពសន្ថវៈ[1]។ បុរសដែលគាំទ្រខ្លាំងបំផុតដល់អំពើពេស្យាចារ ក៏ជាបុរសទាំងឡាយដែលបង្ហាញចេញនូវអត្តសញ្ញាណជាអ្នកត្រួតត្រា។ បុរសបែបនោះ តែងតែគិតថា ការប្រើអំណាចគ្របសង្កត់លើគេ មានសារៈសំខាន់ណាស់ នៅក្នុងទំនាក់ទំនងស្នេហា ហើយគេមើលឃើញទំនាក់ទំនងជាមួយស្រ្តី នៅក្នុងលក្ខខណ្ឌជាគូបដិបក្សទៅវិញ ។ បុរសដែលបង្ហាញចេញនូវអត្តសញ្ញាណជាអ្នកត្រួតត្រា ក៏មានទំនោរជឿរឿងមិនពិតទាក់ទងនិងការរំលោភ សេពសន្ថវៈ (ឧទា. ពួកគេជឿថា ស្រ្តីតែងនិយាយបដិសេដចំពោះរឿងរួមភេទ តែការ ពិតគេមានន័យថាយល់ព្រម ហើយស្រ្តីដែលស្លៀកពាក់លេចលើលេចក្រោម គឺមានបំណងអោយគេរំលោភ )។

---

[1] មិនមានភស្តុតាងបញ្ជាក់ថាមានពេស្យាចារជួយបង្ការការរំលោភទេ។ ផ្ទុយទៅវិញ ពេស្យាចារតាមច្បាប់ ហាក់បីដូចជាមានទំនាក់ទំនងជាមួយនឹងអត្រាខ្ពស់នៃការរំលោភចំពោះស្ត្រី នៅក្នុងចំណោមប្រជាពលរដ្ឋទូទៅ ។

ការសិក្សាបានរកឃើញថា បុរសដែលទិញស្ត្រីមករួមភេទ ជាទូទៅគឺគ្មានការយល់ចិត្តចំពោះស្ត្រី មិនយល់ពីអារម្មណ៍អវិជ្ជមានរបស់ស្ត្រី ដែលស្ត្រីបាននិយាយក្នុងពេលបំរើសេវាផ្លូវភេទ ។ បុរសភាគច្រើននៅក្នុងការសិក្សា បានប្រាប់យើងថា បន្ថែមទៅលើសកម្មភាពហឹង្សាទៅលើស្ត្រី ដែលគេបានទិញសេវាផ្លូវភេទ គេក៏បានធ្វើសកម្មភាពរួមភេទយ៉ាងកាចសាហាវ ទៅលើដៃគូដែលមិនមែនជាអ្នករកស៊ីផ្លូវភេទផងដែរ ។

អ្នកទិញផ្លូវភេទស្ទើរតែទាំងអស់បានប្រើ រូបភាពវីដេអូរឿងភេទ ។ បុរសដែលបានមើលរូបភាពវីដេអូរឿងភេទច្រើន ជាអ្នកដែលបានទិញសេវាផ្លូវភេទញឹកញាប់។ បុរសដែល បានមើលរូបភាពវីដេអូរឿងភេទដែលមានហឹង្សាច្រើន បានរាយការណ៍ថា តែងតែប្រព្រឹត្តនូវឥរិយាបថរួមភេទបែបបង្ខំ ទាំងទៅលើស្ត្រីរកស៊ីផ្លូវភេទ និងដៃគូរដែលមិនមែនជាអ្នករកស៊ីផ្លូវភេទ។ បុរសភាគច្រើនបានពន្យល់ថា គេធ្វើតាមអ្វីដែលគេឃើញនៅក្នុងវីដេអូរឿងភេទ ជាមួយអ្នករកស៊ីផ្លូវភេទដែលគេបានទិញ ។

ផ្នែកសំខាន់នៃការសិក្សាស្រាវជ្រាវនេះ គឺការបង្កើននូវការយល់ដឹងកាន់តែច្បាស់ អំពីការរួមភេទបូកជាមួយអ្នករកស៊ីផ្លូវភេទ ដែលអ្នកខ្លះគិតថាវាជាទម្រង់នៃការរំលោភបំពានខាងផ្នែកយេនឌ័រ ពិសេសមួយសម្រាប់កម្ពុជា ។ បើតាមការឆ្លើយឿបរាប់របស់បុរសចំពោះការសម្ភាសន៍ និងតាមការវិភាគទៅលើស្ថិតិនោះ វាបានបង្ហាញច្បាស់ណាស់ថា ការមើលរូបភាពវីដេអូរឿងភេទនៃការរំលោភបូក ពីវប្បធម៌ផ្សេងៗ (ជាពិសេសពីប្រទេសលោកខាងលិច ជប៉ុន ចិន និង ថៃ) គឺមានឥទ្ធិពលខ្លាំងទៅលើការសម្រេចចិត្តរបស់បុរសខ្លះ ដើម្បីប្រព្រឹត្តការរំលោភបូកជាមួយស្ត្រីរកស៊ីផ្លូវភេទ ។ បុរសខ្មែរជាច្រើន បានរាយករណ៍អោយដឹងថា គេបានមើលវីដេអូផ្លូវភេទអំពីការរំលោភបូក ពីវប្បធម៌ផ្សេងៗ ហើយគេបានធ្វើតាមអ្វីដែលគេបាន

*មើលឃើញនីក្នុងវីដេអូ នៅពេលដែលគេប្រព្រឹត្តការរួមភេទបូកជាមួយ អ្នករកស៊ីផ្លូវភេទ និងជាមួយដៃគូដែលមិនមែនជាអ្នករកស៊ីផ្លូវភេទ ។*

*អ្នកទិញសេវាផ្លូវភេទបានបញ្ជាក់ថា ប្រសិទ្ធិភាពដែលអាចបង្អាក់ពួកគេក្នុងការទៅរកសេវាផ្លូវភេទ គឺការដាក់ពិន័យជាបទឧក្រិដ្ឋ និងការបង្ហាញអោយសាធារណៈជនបានឃើញ ។ ផ្អែកទៅលើការសិក្សានេះ អនុសាសន៍ដែលផ្តល់ជូនរួមមាន ការជំរុញអនុវត្តច្បាប់ដែលទាក់ទងទៅនឹងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ហើយជាមួយគ្នានេះដែរគឺមិនដាក់ទណ្ឌកម្មដល់អ្នករកស៊ីផ្លូវភេទ ផ្តល់កម្មវិធីអប់រំអំពីការបំពុលដ៏រាក់រាំនៃរូបភាពវីដេអូរឿងភេទនៅក្នុងវប្បធម៌ខ្មែរ ព្រមទាំងកម្មវិធីអប់រំនិងបង្ការសម្រាប់យុវជន ប្រឆាំងនិងទស្សនៈដែលយល់ឃើញថាទាល់តែទិញសេវាផ្លូវភេទ ទើបជាមនុស្សប្រុសពិតប្រាកដនោះ ។*

## សេចក្តីសង្ខេប និងអនុសាសន៍

*របាយការណ៍នេះ បានពិពណ៌នាអំពីការយល់ដឹងដ៏ទូលំទូលាយរបស់ អ្នកទិញសេវាផ្លូវភេទខ្មែរ អំពីឧស្សាហកម្មផ្លូវភេទ អំពីការជួញដូរមនុស្ស អំពីឥទ្ធិពលនៃរូបភាពវីដេអូរឿងភេទទៅលើការទិញសេវាផ្លូវភេទ និងអំពីការដែលអាចធ្វើអោយគេមានការខ្មាចញញើតក្នុងការទិញសេវាផ្លូវភេទ ។ យើងបានធ្វើការសង្ខេប នូវរបកគំហើញជាច្រើនទាំងផ្នែកគុណភាព និងបរិមាណ ទាក់ទងទៅនឹងឥរិយាបថរបស់បុរសទាំងនេះ ចំពោះស្ត្រី ។ បុរសទាំងនេះបាននិយាយដោយឥតលាក់លៀម និងស្មោះត្រង់គួរអោយកត់សំគាល់ ជាមួយនឹងអ្នកសម្ភាសន៍របស់យើង ។ ជួនកាលគេនិយាយថា នេះជាលើកទីមួយហើយ ដែលគេនិយាយអំពីបទពិសោធន៍របស់គេជាមួយនឹងស្ត្រីរកស៊ីផ្លូវភេទ ហើយដែលពីមុនមក គេមិនដែលបានចែកចាយព័ត៌មាននោះជាមួយអ្នកណាម្នាក់ទេ។ នៅពេលចុងបញ្ចប់នៃការសម្ភាសន៍មួយ មានបុរសម្នាក់បាននិយាយថា " ខ្ញុំមានអារម្មណ៍ថាដូចបានដកបន្ទាចេញពីក្នុងទ្រូងអញ្ចឹង " ។*

បុរសម្នាក់ទៀតដែលយើងបានសម្ភាសន៍ បាននិយាយថា " ខ្ញុំសង្ឃឹមថា ការសិក្សាស្រាវជ្រាវនេះ ទទួលបានជោគជ័យ ដើម្បីជួយស្ត្រីដែលរងគ្រោះ បានចាកចេញផុតពីមុខរបរបែបនោះ និងជួយរំលឹកដល់បុរសទាំងឡាយ កុំអោយទៅរកសេវាផ្លូវភេទទៀត ពីព្រោះមានស្ត្រីខ្លះមិនចង់ធ្វើដូច្នោះទេ តែនាងត្រូវគេបោកបញ្ឆោត" ។ ខាងក្រោមនេះគឺជាចំនុចសំខាន់ៗខ្លះ នៃរបាយការណ៍ ។

១. អ្នកទិញសេវាផ្លូវភេទបានដោះសារ ចំពោះការទិញស្ត្រីមកបម្រើផ្លូវភេទ របស់គេ ដោយការប្រមាថមើលងាយហាក់បីដូចជាស្ត្រីរកស៊ីផ្លូវភេទមិនមែនជាមនុស្ស ហើយស្តីបន្ទោសចំពោះភាពរងគ្រោះរបស់គ្នា (មានបុរសម្នាក់បាននិយាយអោយស្ត្រីទាំងនោះថាជា "មនុស្សចិត្តទន់ខ្សោយ" ។ បុរសជាច្រើនបានគិតថាស្ត្រីរកស៊ីផ្លូវភេទ គឺពិតជាខុសប្លែកពីមនុស្សទូទៅផ្សេងទៀត ។ បុរសបាននិយាយបង្ហាញអំពី សេវាផ្លូវភេទ ដោយលើកឡើងថាសេវាផ្លូវភេទបានជួយកាត់បន្ថយនូវអំពើរំលោភសេពសន្ថវៈទៅលើស្ត្រីដ៏ទៃផ្សេងទៀតដែលមិនមែនជាអ្នករកស៊ីផ្លូវភេទ បើទោះបីជាការលើកឡើងនោះគ្មានភស្តុតាងអ្វីមកបញ្ជាក់ពីជំនឿដូច្នោះក៏ដោយ ។ ពួកគេមិនគិតថាស្ត្រីរកស៊ីផ្លូវភេទក៏អាចត្រូវគេរំលោភដែរនោះទេ ។ វិធីមួយដែលយើងអាចផ្លាស់ប្តូរនូវឥរិយាបថអវិជ្ជមានចំពោះស្ត្រីក្នុងសេវាផ្លូវភេទបាន គឺផ្លាស់ប្តូរការផ្តោតគំនិតនៃការនិយាយពីស្ត្រី ទៅផ្តោតលើការពិភាក្សាពីបុរសដែលជាអ្នកទិញសេវាវិញម្តង ។ នៅពេលនេះ សំណួរដែលក្តៅគគុកនោះមិនមែនជាសំណួរដែលថា "តើកត្តាអ្វីខ្លះដែលនាំអោយស្ត្រី មកបំរើផ្លូវភេទដើម្បីលុយ?" នោះទេ ។ យើងបានដឹងចំលើយចំពោះសំណួរនេះរួចទៅហើយថា - នាងចូលទៅក្នុងមុខរបរពេស្យាចារ មិនមែនដោយសារកង្វះខាតខាងសីលធម៌ទេ ប៉ុន្តែដោយសារនាងគ្មានជម្រើសផ្សេងដើម្បីចិញ្ចឹមជីវិត ។ សំណួរដែលយើងត្រូវសួរគឺ "តើមានកត្តាអ្វីខ្លះ ដែលនាំអោយបុរសទៅទិញសេវាផ្លូវភេទ?" នោះវិញទេ ។

២. បុរសស្ទើរតែទាំងអស់ (៩៨%) បានប្រើប្រាស់សេវាស្ត្រីរកស៊ីផ្លូវភេទ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់មេបន ។ ការធ្វើជាមេបន គឺមានការពាក់ព័ន្ធទៅនឹងភាគីទីបីក្នុងការគ្រប់គ្រងលើស្ត្រី ដែលភាគច្រើនគឺត្រូវទៅនឹងនិយមន័យផ្លូវច្បាប់នៃអំពើ ជួញដូរមនុស្ស ។ បុរសភាគច្រើន (៨៥%) បានឃើញពីអំពើហឹង្សាលើរាងកាយ ការគំរាមកំហែងដោយពាក្យសំដី និងការបង្ខំបក្សពួកក្រោមបង្គាប់អោយប្រព្រឹត្តបទឧក្រិដ្ឋទៅលើស្ត្រីរកស៊ីផ្លូវភេទ ។ នៅកម្ពុជា ក៏ដូចជានៅបណ្តាប្រទេសផ្សេងៗទៀតដែរ វាជាការពិបាកក្នុងការញែកចេញឱ្យដាច់ពីគ្នា នូវអ្វីដែលគេគិតថាជា "ការរកស៊ីផ្លូវភេទធម្មតា" និងការជួញដូរផ្លូវភេទ ។ វាមិនអាចកើតមាននូវអំពើជួញដូរ ដោយគ្មានកន្លែងជាគោលដៅធ្វើចរាចរស្ត្រីទៅនោះទេ ។ ទីកន្លែងដែលជាគោលដៅនៃអំពើជួញដូរ គឺជាទីតាំងដែលមានពេស្យាចារ។

៣. បុរសខ្មែរភាគច្រើន (៨៣%) ក្នុងចំណោម១៣៣នាក់ ដែលយើងបានសម្ភាសន៍ មានប្រពន្ធឬសង្សារ ។ ហេតុផលរបស់គេដែលប្រើសេវាផ្លូវភេទ ភាគច្រើនសាមញ្ញទេ គឺដើម្បីបំពេញចំណង់ផ្លូវភេទរបស់គេ។ ហេតុផលផ្សេងទៀតដែលគេផ្តល់ចំពោះការដែលគេប្រើសេវាផ្លូវភេទរួមមាន: ដើម្បីអោយប្លែក ឬក៏ដើម្បីសាកល្បងធ្វើទៅតាមអ្វីដែលគេបានឃើញនៅក្នុងរូបភាពវីដេអូរឿងភេទ ។

៤. បុរសភាគច្រើនបានទិញសេវាផ្លូវភេទជាលើកដំបូង នៅពេលដែលគេមានអាយុប្រហែល២០ឆ្នាំ ។ ជាធម្មតា គេទៅផ្ទះបនទាំងលើកដំបូងនិងលើកក្រោយៗមកទៀត ទោះជាយ៉ាងណា ក៏បុរសទាំងនោះនៅបានទិញសេវាផ្លូវភេទតាមក្លឹបខារ៉ាអូខេ សណ្ឋាគារ រង្គសាល ហាងម៉ាសារ និងខ្ទឹបរាំស្រាត ផ្សេងៗទៀតដែរ ។

៥. បុរសដែលយើងបានសម្ភាសន៍ បានប្រើសេវាផ្លូវភេទជាញឹកញាប់។ បុរសស្ទើរតែទាំងអស់ (៩១%) បានប្រើប្រាស់សេវាផ្លូវភេទយ៉ាងហោចណាស់ម្តង ក្នុងមួយខែ ។ នៅពេលដែលគេប្រើសេវាផ្លូវភេទ នៅតាមកន្លែងនានានោះ បុរសជាញឹកញាប់បំផុត

(៩៨%) ប្រើសេវាផ្លូវភេទនៅតាមផ្ទះបន ។ បញ្ហានេះបញ្ជាក់ឱ្យឃើញថា ផ្ទះបនដែលផ្តល់សេវាផ្លូវភេទ នៅមាននៅឡើយនៅ ភ្នំពេញ ។

៦. មានបុរសប្រហែលពាក់កណ្តាល តែងតែស្ថិតក្នុងភាពស្រវឹង នៅពេលដែលគេទៅរកសេវាផ្លូវភេទ ។ ភាពទាក់ទងគ្នារវាងគ្រឿងស្រវឹងឬការប្រើគ្រឿងញៀន ការអូសទាញពីមិត្តភក្តិដែលថាដើម្បីបង្ហាញពីភាពជាបុរសគឺទាល់តែរកសេវាផ្លូវភេទ និងការប្រើប្រាស់រូបភាពវីដេអូរឿងភេទដែលបង្ហាញពី "ប្រក្រតីភាព" នៃបញ្ហាពេស្យាចាររួមទាំងការរំលោភបូកផងនោះ គួរតែដាក់បញ្ចូលទៅក្នុងយុទ្ធនាការអប់រំ។ បុរសជាច្រើនបាននិយាយជាមួយយើង អំពីតម្រូវការក្នុងការអប់រំ ស្តីអំពីទុក្ខទោសនៃអំពើពេស្យាចារ ។ នៅពេលពួកគេបានយល់ដឹងអំពីគ្រោះថ្នាក់ នៃការឆ្លងជំងឺកាមរោគផ្សេងៗ ពួកគេមិនបានទទួលការអប់រំអំពីការខូចខាតខាងផ្លូវចិត្តចំពោះស្ត្រីដោយសារតែបញ្ហាពេស្យាចារនោះទេ ។ លើសពីនេះទៅទៀត ពួកគេមិនបានដឹងពីការខូចខាតទំនាក់ទំនងរបស់ពួកគេ ជាមួយប្រពន្ធ និងសង្សាររបស់ខ្លួនដែលអាចបណ្តាលមកពីការទៅរកសេវាផ្លូវភេទ របស់គេនោះទេ។

៧. ប្រហែលមួយភាគបីនៃអ្នកទិញសេវាផ្លូវភេទទាំងនោះ ធ្លាប់ធ្វើជាទាហាន ។ មួយភាគធំ (៧០%) នៃបុរសទាំងនោះ បានប្រើប្រាស់សេវាផ្លូវភេទ នៅពេលដែលគេកំពុងធ្វើជាទាហាន ។ ដូចនៅក្នុងបណ្តារប្រទេសផ្សេងៗទៀតដែរ ការប្រើប្រាស់សេវាផ្លូវភេទនៅក្នុងកងកំលាំងយោធាកម្ពុជា បានទទួលការយោគយល់យ៉ាងច្រើន ។

៨. អ្នកទិញសេវាផ្លូវភេទ ៩៩ភាគរយ នៅក្នុងការសិក្សានេះបានមើលរូបភាពវីដេអូរឿងភេទ ដែលភាគច្រើនគឺមើលតាមទូរស័ព្ទចល័ត និងតាមវីដេអូ ។ ការមើលរូបភាពវីដេអូរឿងភេទញឹកញាប់គឺជាកត្តាមួយ ក្នុងចំណោមកត្តាជាច្រើន ដែលមានទំនាក់ទំនងជាមួយនឹងការទិញសេវាផ្លូវភេទរបស់បុរស ។ នៅក្នុងការសិក្សានេះបុរសដែលមើលរូបភាពវីដេអូរឿងភេទញឹកញាប់បំផុត ក៏ជាអ្នកដែលទៅរកសេវា

ស្ត្រីរកស៊ីផ្លូវភេទញឹកញាប់ណាស់ដែរ ។ បុរសទាំងនោះបានប្រាប់យើងជាច្រើនដង ថាសកម្មភាពរួមភេទរបស់គេកាន់តែដូចទៅនឹងសកម្មភាពរួមភេទ ដែលគេបានមើល នៅក្នុងរូបភាពវីដេអូរឿងភេទ ។ ស្ត្រីនៅក្នុងរូបភាពវីដេអូរឿងភេទ ដែលគេបានមើល ភាគច្រើនគឺជាជនជាតិស្បែកសមកពីអឺរ៉ុប ជប៉ុន ចិន និង ថៃ ។ ការសិក្សានេះ វាកាន់តែបានផ្តល់នូវភាពរឹងមាំ ទៅដល់ការអង្កេតពីមុនមកដែលថា រូបភាពវីដេអូ រឿងភេទ អំពើពេស្យាចារ និង អំពើហឹង្សាផ្លូវភេទ ពិតជាមានទំនាក់ទំនងគ្នាយ៉ាង ខ្លាំង ពិតប្រាកដមែន។ វាពិតជាទំនងណាស់ដែលថា រូបភាពវីដេអូរឿងភេទ មកពី បរទេសបានរួមចំណែក និងគាំទ្រដល់អំពើហឹង្សាផ្លូវភេទលើស្ត្រីនិងកុមារដែលកើត មាននៅក្នុងប្រទេសកម្ពុជា ។ នៅពេលដែលពុំមានកម្មវិធីអប់រំអំពីផ្លូវភេទដែលសម ស្របទៅតាមវប្បធម៌នោះ រូបភាពវីដេអូរឿងភេទនឹងដើរតួនាទីអប់រំផ្លូវភេទ ។

រូបភាពវីដេអូរឿងភេទ វាជាទម្រង់មួយនៃអំពើហឹង្សាប្រឆាំងនឹងស្ត្រីនិងកុមារ រួចទៅហើយ ដោយសារថាស្ត្រីនិងកុមារទាំងនោះគឺជាអ្នក ដែលរងទុក្ខទោសអន្តរាយ ពីការដែលត្រូវគេយកមកផលិតរូបភាពវីដេអូរឿងភេទទាំងនោះ។ រូបភាពវីដេអូរឿង ភេទ ក៏មានទំនាក់ទំនងជាមួយអំពើរហឹង្សាផ្លូវភេទផ្សេងៗទៀតដែរ (Malamuth & Pitpitan, 2007; Monto & McRee, 2005; Hald, Malamuth & Yuen, 2010)។ ការសិក្សា ផ្សេងៗទៀត ក៏នៅបានរកឃើញពីទំនាក់ទំនងរវាងរូបភាពវីដេអូរឿងភេទ និងការ រំលោភបំពានផ្លូវភេទផងដែរ (Malamuth, Addison, & Koss, 2000; Malamuth & Pitpitan, 2007; Monto & McRee, 2005; Hald, Malamuth & Yuen, 2010). លោក Busch និងសហការីរបស់គាត់ (2002) បានរកឃើញថាបុរសដែលត្រូវបានគេចាប់ខ្លួននៅ សហរដ្ឋអាមេរិក ពីបទបានអូសទាញជនដ៏ទៃក្នុងគោលដៅប្រព្រឹត្តអំពើពេស្យាចារ សុទ្ធតែជាអ្នកដែលតែងតែមើលរូបភាពវីដេអូរឿងភេទជាប្រចាំ ។ ឥទ្ធិពលអវិជ្ជមាន របស់រូបភាពវីដេអូរឿងភេទមកលើអ្នកដែលបានមើលយ៉ាងជោគជាំនោះ នៅពុំទាន់ មានការសិក្សានៅឡើយទេ។ ការសិក្សាថ្មីមួយបានអោយដឹងថា ការក្រេចញទឹកកាម

លឹង្គខ្សោយ តម្រូវការនឹករវើរវាយអំពីរូបភាពវីដេអូរឿងភេទដើម្បីរក្សាអារម្មណ៍ផ្លូវភេទ(រក្សារលឹង្គឱ្យរឹង)បានយូរ និងភាពព្រងើយបន្តើយពីដៃគូរបស់ខ្លួនបន្តិចម្តងៗនោះ គឺពិតជាមានការទាក់ទងជាមួយនឹងការទស្សនារូបភាពវីដេអូរឿងភេទ របស់បុរស (Rothbart, 2012)។

៩. អ្នកដែលយើងបានសម្ភាសន៍ចំនួន ៤១ ភាគរយ បានប្រព្រឹត្តអំពើរំលោភបូកជាមួយអ្នករកស៊ីផ្លូវភេទ ។ នៅពេលដែលអ្នកទិញសេវាផ្លូវភេទខ្លះ ទទួលស្គាល់ចារិតដែលចូលចិត្តរួមភេទដូចគ្នាចំពោះការអនុវត្តបែបនេះ បុរសភាគច្រើន បានបញ្ជាក់ពីចំណងមិត្តភាពរវាងមិត្តភក្តិរបស់គេ ដែលកើតមានក្នុងកំឡុងពេលរួមភេទបូកជាមួយអ្នករកស៊ីផ្លូវភេទ។ អ្នកដែលបានរាយការណ៍ថាគេបានចូលរួមដោយផ្ទាល់ក្នុងការរួមភេទបូក ឬក៏ជាគ្រាន់តែបានដឹងថាមានអំពើរួមភេទបូកកើតឡើង បានខំនិយាយបិទបាំងនូវអំពើហឹង្សាដ៏ហួសហេតុ ដោយខំបង្ហាញឱ្យឃើញថាវាកើតឡើងតិចតួចបំផុត ។ ការរួមភេទបូកជាមួយអ្នករកស៊ីផ្លូវភេទ បើយោងទៅតាមបុរសទាំងនោះ វាមិនដែលមានកើតឡើងទេនៅក្នុងប្រវត្តិសាស្ត្រនៅក្នុងប្រទេសកម្ពុជា។ អ្នកនិពន្ធ ក៏មិនច្បាស់ទេថា តើការរួមភេទបូកបែបនេះ កើតមានឡើងនៅកម្ពុជាចាប់តាំងពីពេលណាមកនោះ។ មិនថាគេរៀនពីវីដេអូរឿងភេទឬក៏អត់ទេ ប៉ុន្តែការទស្សនាវីដេអូរឿងភេទនៃការរួមភេទបូកពីវប្បធម៌ផ្សេងៗ របស់បុរស បានគាំទ្រយ៉ាងខ្លាំងដល់ការរួមភេទបូក ។ នៅក្នុងការរកស៊ីផ្លូវភេទ នៅពេលដែលស្ត្រីមិនអាចចៀសផុតពីអំពើហឹង្សា ពួកគេយល់ព្រមទទួលយកនូវអ្វីដែលគេដឹងថាជាការឈឺចាប់ដែលមិនអាចចៀសវាងបាន និងព្យាយាមដើម្បីកាត់បន្ថយនូវគ្រោះថ្នាក់នោះ បើសិនជាគេអាចធ្វើទៅបាន ។ ដើម្បីបញ្ជាក់អំពីភាពគ្មានអំណាចរបស់ស្ត្រី ក្នុងការរួមភេទបូក បុរសម្នាក់បានពន្យល់ថា: *"បន្ទាប់ពីយើងបានបង់លុយឲ្យមេបន ដើម្បីយកស្រីចេញទៅដេក យើងបាននិយាយប្រាប់នាងថា យើងត្រូវការរួមភេទបូក តើនាងព្រមឬទេ ។ នាងបាននិយាយថា នាងយល់ព្រម ដូច្នេះយើងក៏យកនាងទៅ"*។

១០. ដូចនៅក្នុងវប្បធម៌ផ្សេងៗទៀតដែរ បុរសខ្មែរបានសម្តែងចេញនូវយោបល់ផ្ទុយគ្នា អំពីការទិញសេវាផ្លូវភេទ ។ ចំណុចនេះបានផ្តល់ឱកាសសម្រាប់ធ្វើអន្តរាគមន៍និងការផ្លាស់ប្តូរ។ អ្នកដែលយើងបានសម្ភាសន៍ មួយចំនួនបានចាត់ទុកអំពើពេស្យាចារថាជារឿងធម្មតា ប៉ុន្តែម្យ៉ាងទៀត ពួកគេចំនួន៨៩% បានចាត់ទុកអំពើពេស្យាចារ ថាជាការកេងប្រវ័ញ្ចផ្លូវភេទ ។ បុរសនៅក្នុងការសិក្សានេះបានពណ៌នាពីសកម្មភាពរបស់ពួកគេក្នុងការប្រើសេវាផ្លូវភេទថា ជាកំហុស ជាការបាត់បង់កិត្តិយស និងធ្វើឲ្យតម្លៃនៃវប្បធម៌ខ្មែរធ្លាក់ចុះ ។ មានអ្នកដែលយើងបានសម្ភាសន៍ម្នាក់ សំណូមពរអោយបង្កើតនូវកម្មវិធីអប់រំដល់យុវជននៅតំបន់ជនបទ អំពីឥទ្ធិពលអាក្រក់នៃរូបភាពវីដេអូរឿងភេទ ។ កម្មវិធីមគ្គុទ្ទេសក៍សម្រាប់យុវជនជាច្រើន ឧទាហរណ៍ដូចជាកម្មវិធីដែលបានបង្កើតដោយ សម្ព័ន្ធភាពប្រឆាំងការជួញដូរស្ត្រីតំបន់អាស៊ីប៉ាស៊ីហ្វិក នៅទីក្រុងមានីល គឺជាឧទាហរណ៍ដ៏វិជ្ជមានមួយ ចំពោះកម្មវិធីអប់រំបែបនោះ ។ ពេលដែលមានបុរសខ្លះបានយល់ដឹង ពីអំពើហឹង្សាខ្លះៗនៅក្នុងការរកស៊ីផ្លូវភេទ និងភាពក្រីក្រគួឲ្យអស់សង្ឃឹមរបស់ស្ត្រីដែលគេទិញសេវា ជាមួយនិងភាគច្រើនបានសង្កេតឃើញនូវអំពើហឹង្សាពីមេបនចំពោះស្ត្រីរកស៊ីផ្លូវភេទ ការគ្រាន់តែដឹងប៉ុណ្ណោះវាមិនគ្រប់គ្រាន់ទេ ដើម្បីធ្វើឲ្យគេផ្លាស់ប្តូរការប្រព្រឹត្តរបស់គេនោះ ។

១១. យោងតាមបុរសដែលយើងបានសម្ភាសន៍ អ្វីដែលអាចធ្វើឲ្យគេខ្លាចញញើតចំពោះការទិញសេវាផ្លូវភេទនោះ រួមមានការដាក់ទោសព្រហ្មទ័ណ្ឌធ្ងន់ធ្ងរបំផុត ឬក៏យកឈ្មោះពួកគេទៅផ្សព្វផ្សាយជាសាធារណៈ ។ បើទោះបីជាមានកំរិតទាបក្នុងការធ្វើឲ្យមានការខ្លាចញញើតនោះ ក៏នៅមានបុរស ៣ ភាគ ៤ បាននិយាយថា កម្មវិធីអប់រំ ក៏អាចជួយរារាំងបុរសពីការទិញសេវាផ្លូវភេទដែរ ។ នៅក្នុងប្រទេសជាច្រើនច្បាប់ស្តីពីការជួញដូរនិងពេស្យាចារ អនុវត្តមិនទាន់បានទៀងទាត់ទេ។ យើងមានការពេញចិត្ត ចំពោះនិទណ្ឌភាពដល់ស្ត្រីរកស៊ីផ្លូវភេទ ពីព្រោះថា ផ្អែកទៅលើព័ត៌មាននៅក្នុងរបាយការណ៍នេះ និងផ្អែកទៅលើការស្រាវជ្រាវជាច្រើនទៀត ស្ត្រីទទួល

រងគ្រោះនិងទុក្ខទោសពន់ពេកណាស់ពីអំពើពេស្យាចារនេះ ដែលនោះគឺជាអំពើរំលោភសិទ្ធិមនុស្ស ។ ដោយសារថា ការទិញសេវាផ្លូវភេទគឺជាមូលហេតុបណ្ដាលឲ្យមានទុក្ខវេទនាដល់អ្នករកស៊ីផ្លូវភេទនោះ យើងគាំទ្រអោយមានការដាក់ទោសចំពោះអ្នកទិញសេវាផ្លូវភេទ ។

ការពិភាក្សាលើការឆ្លើយតប ចំពោះការរំលោភសិទ្ធិមនុស្សទៅលើ អ្នករកស៊ីផ្លូវភេទនៅក្នុងផ្ទះបន មន្ត្រីរបស់អង្គការមិនមែនរដ្ឋាភិបាលម្នាក់ ពីអង្គការ LICADHO បាននិយាយថា "... អ្វីដែលខ្ញុំចង់ឃើញបំផុតនោះគឺ ការបំបែករចនាសម្ព័ន្ធនៃបណ្ដាញនេះ ។ យើងមិនមែនគ្រាន់តែនិយាយអំពីឪពុកម្ដាយដែលលក់កូន មេបនលក់ក្មេង... តែគឺយើងនិយាយអំពីអ្នកដែលបានទទួលផលប្រយោជន៍ និងអនុញ្ញាត្តិអោយគ្រឹះស្ថានទាំងនេះដំណើរការ..." (Unmacht, 2003). ។

អ្នកទិញសេវាផ្លូវភេទមួយចំនួន នៅក្នុងការសិក្សានេះ បានចៀសវាងការរាយការណ៍ ពីអំពើហឹង្សា និងការរំលោភបំពាន ទៅដល់អាជ្ញាធរ ពីព្រោះពួកគេខ្លាចមានការសងសឹកមកវិញ ។ នាយករដ្ឋមន្ត្រីកម្ពុជា សម្ដេច ហ៊ុន សែន បានបង្ហាញចំៗចំពោះការប្រព្រឹត្តមិនត្រឹមត្រូវរបស់មន្ត្រីជាន់ខ្ពស់ ក្នុងកិច្ចខិតខំប្រឹងប្រែងប្រឆាំងការជួញដូរ ដោយលោកបានលើកឡើងថា " ខ្ញុំមានការសោកស្ដាយជាខ្លាំង ចំពោះការប្រព្រឹត្តខុសឆ្គង របស់អ្នកដឹកនាំខ្លះ ដែលបានជ្រៀតជ្រែកការងារតុលាការ និងមន្ត្រីដែលជំរុញការអនុវត្តច្បាប់ ... ។ វប្បធម៌និទណ្ឌភាពគឺមិនអាចទទួលយកបានទេ" (Vong & Khouth, 2010)។ អ្នកទិញសេវាផ្លូវភេទម្នាក់ដែលយើងបានសម្ភាសន៍នៅក្នុងការសិក្សានេះ បាននិយាយថា "អ្នកដែលទៅរកសេវាផ្លូវភេទ ត្រូវតែរកចាប់ធ្វើការចោទប្រកាន់ ដាក់ពន្ធនាគារ ហើយត្រូវតែធ្វើឱ្យប្រាកដថា គ្មាននរណាម្នាក់អាចសូកប៉ាន់ ដើម្បីបានរួចខ្លួនទេ"។

*១២. ការទិញសេវាផ្លូវភេទនៅកម្ពុជា ក៏ដូចជានៅប្រទេសផ្សេងទៀតដែរ ត្រូវបានគេចាត់ទុកថាជាក្បួនចំលង់មួយ និងបង្ហាញអោយឃើញពីភាពជាបុរស ។ ការផ្លាស់ប្តូរឥរិយាបថសង្គម អំពីភាពជាប្រុស និងបញ្ហាផ្លូវភេទ អាចកើតឡើង ដោយការធ្វើយុទ្ធនាការអប់រំជាសាធារណៈ និងដោយបង្កើននូវការជំរុញការអនុវត្តច្បាប់ប្រឆាំងអំពើហឹង្សាចំពោះស្ត្រី ដែលមានស្រាប់ ។ បង្កើននូវការជំរុញការអនុវត្តច្បាប់ប្រឆាំងការទិញសេវាផ្លូវភេទ គឺជាមធ្យោបាយដោយត្រង់តែម្តង់ក្នុងការកាត់បន្ថយនូវការជួញដូរផ្លូវភេទ ។ អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ស្តីអំពីសិទ្ធិរបស់អ្នករងគ្រោះនៃអំពើជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារ លោកស្រី* Sigma Huda *បានសង្កេតឃើញថា "បញ្ហានៃតម្រូវការ គឺជាចំណុចសំខាន់ណាស់ ក្នុងការដោះស្រាយបញ្ហាជួញដូរមនុស្ស " លោកស្រីក៏បានកត់សំគាល់ទៀតថា " ដោយបានចូលរួមក្នុងសកម្មភាពអាជីវកម្មផ្លូវភេទ អ្នកប្រើប្រាស់សេវាផ្លូវភេទ...បានធ្វើឱ្យមានទុក្ខទោសបន្ថែមដោយផ្ទាល់ និងបង្កនូវភាពអន្តរាយកាន់តែច្រើន ចំពោះជនរងគ្រោះដោយអំពើជួញដូរ ដូចគ្នានឹងអំពើរំលោភសេពសន្ទវៈដែរ បន្ថែមទៅលើមធ្យោបាយពោរពេញដោយគ្រោះថ្នាក់ជាច្រើនទៀត ដែលប្រព្រឹត្តដោយ អ្នកដទៃផ្សេងទៀតដើម្បីនាំយកជនរងគ្រោះចូលមក និងបន្តរស្ថិតនៅក្នុងការងារផ្លូវភេទ "*[2] ។

---

[2] *គណៈកម្មាធិការសិទ្ធិមនុស្ស របស់អង្គការសហប្រជាជាតិ (២០០៦) របាយការណ៍របស់អ្នករាយការណ៍ពិសេស ស្តីអំពីសិទ្ធិរបស់អ្នករងគ្រោះនៃអំពើជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារ*, 9 U.N. Doc. E/CN.4/2006/62 (Feb. 20, 2006)។ *អ្នករាយការណ៍ ពិសេសក៏បានកត់សំគាល់ទៀតថា "ពាក្យ "ការងារផ្លូវភេទ" "អ្នករកស៊ីផ្លូវភេទ" និង "អតិថិជន" បានធ្វើអោយមានការយល់ខុសឆ្គងថា ពេស្យាចារ ដូចដែលបានអនុវត្តនៅពេលនេះ គឺមិនស្ថិតនៅក្នុងប្រភេទនៃការជួញដូរមនុស្សទេ "*